# ទិវាអន្តរជាតិ

# ស្តីពីជនជាតិដើមភាគតិចពិភពលោក

**សេចក្តីថ្លែងការណ៍ដោយលោកស្រី ទីយ៉ុង វ៉ា តាំង ឧត្តមស្នងការស្តីទីទទួលបន្ទុកសិទ្ធិមនុស្ស និងលោក អេស ចេមស៍ អាណាយ៉ា អ្នករាយការណ៍ពិសេសស្តីស្ថានការណ៍សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ជនជាតិដើមភាគតិច**

*ទីក្រុងហ្សឺណែវ :-* ទិវាអន្តរជាតិស្តីពីជនជាតិដើមភាគតិចពិភពលោកឆ្នាំនេះ ដែលនឹងត្រូវប្រារព្ធធ្វើនៅថ្ងៃទី៩ ខែសីហា គឺជាទិវាដំបូងបង្អស់បន្ទាប់ពីការអនុម័តជាប្រវត្តិសាស្ត្រនូវសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិជនជាតិដើមភាគតិចដោយមហាសន្និបាតអង្គការសហប្រជាជាតិក្នុងខែកញ្ញា ឆ្នាំ២០០៧។

សេចក្តីប្រកាសនេះ ជាលទ្ធផលដែលបានមកពីយុទ្ធនាការមិនចេះនឿយហត់របស់ជនជាតិដើមភាគតិចរយៈពេលជាងពីរទសវត្សរ៍កន្លងមក — ការព្រាងសេចក្តីប្រកាសនេះ បានចាប់ផ្តើមធ្វើក្នុងឆ្នាំ១៩៨៥ - បានកត់សំគាល់ពីការវិវត្តន៍មួយដ៏សំខាន់ក្នុងការការពារសិទ្ធិរបស់ខ្លួន។

សេចក្តីប្រកាសនេះ ត្រូវបានអនុម័តយល់ព្រមដោយសំលេងភាគច្រើនលើសលុបនៃរដ្ឋសមាជិករបស់អង្គការសហប្រជាជាតិ កំណត់អំពីបទដ្ឋានអប្បបរមាសំរាប់ការរស់រានមានជីវិត សេចក្តីថ្លៃថ្នូរ និងសុខមាលភាពរបស់ជនជាតិដើមភាគតិចប្រមាណជា ៥.០០០ ក្រុម នៅលើពិភពលោក (ដែលមានចំនួនមនុស្សរហូតដល់ ៣៧០ លាននាក់)។ សេចក្តីប្រកាសនេះ មានគោលបំណងដោះស្រាយអំពើអយុត្តិធមិជាប្រវត្តិសាស្ត្រដែលពួកគេបានជួបប្រទះ តាមរយៈការអះអាងជាថ្មីអំពីសិទ្ធិដោយឡែក និងការរស់នៅប្រកបដោយសុខសន្តិភាពនៅលើទឹកដីរបស់ខ្លួន។ សេចក្តីប្រកាសនេះតំណាងផងដែរអំពីការរួមវិភាគទានមួយដ៏សំខាន់ដល់គោលការណ៍ណែនាំស្តីពីយុត្តិធមិ និងសេចក្តីថ្លៃថ្នូរដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិ មនុស្សដែលខួបលើកទី៦០ នៃសេចក្តីប្រកាសនេះនឹងប្រារព្ធធ្វើក្នុងឆ្នាំនេះ។

ទោះជាយ៉ាងណាក៏ដោយ ការអនុម័តសេចក្តីប្រកាសស្តីពីសិទ្ធិជនជាតិដើមភាគតិចនេះ អ្វីដែលសំខាន់នោះគឺសេចក្តីប្រកាសនេះនឹងមិនធ្វើការកែប្រែជីវិតរស់នៅរៀងរាល់ថ្ងៃរបស់បុរស ស្ត្រី និងកុមារ ចំពោះ

សិទ្ធិដែលពួកគាត់មានស្រាប់នោះឡើយ ។ ចំពោះបញ្ហានេះ យើងត្រូវការឱ្យមានការប្តេជ្ញាចិត្តខាងនយោ-បាយរបស់រដ្ឋទាំងអស់ សហប្រតិបត្តិការអន្តរជាតិ ការគាំទ្រ និងសុឆន្ទះរបស់សាធារណៈជនទូទៅ ដើម្បីបង្កើតនិងអនុវត្តកម្មវិធីសំខាន់ជាក់ស្តែងផ្សេងៗដែលត្រូវរៀបចំ និងអនុវត្តដោយមានការពិគ្រោះយោបល់ដោយផ្ទាល់ជាមួយជនជាតិដើមភាគតិច ។

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស — ស្ថាប័នសំខាន់ៗរបស់អង្គការសហប្រជាជាតិដែលទទួលខុសត្រូវចំពោះការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស — និងអ្នករាយការណ៍ពិសេសស្តីពីស្ថានការណ៍សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ជនជាតិដើមភាគតិច ត្រូវប្តេជ្ញាចិត្តធ្វើការជាមួយគ្នាដើម្បីឈានទៅសំរេចបាននូវសិទ្ធិទាំងឡាយដែលមានចែងក្នុងសេចក្តីប្រកាសនេះ ដើម្បីឱ្យជនជាតិដើមភាគតិចទាំងអស់នៅលើពិភពលោកអាចរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ និងសុខសន្តិភាពពិតប្រាកដ ។

*សំរាប់ព័ត៌មានបន្ថែម សូមមើលវិបសាយខាងក្រោមនេះ :*
*http://www2.ohchr.org/english/issues/indigenous/intday2008.htm*

ចប់